## អ្នកប្រយុទ្ធ (combatant)

ឋានៈជាអ្នកប្រយុទ្ធ ត្រូវបានទទួលស្គាល់ តែក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ (international armed conflict)។ អ្នកប្រយុទ្ធ សំដៅដល់បុគ្គល ដែលចូលរួមផ្ទាល់ក្នុងជម្លោះ (directly in hostilities) ដូចជាការប្រព្រឹត្តអំពើសម្លាប់ ធ្វើឲ្យរបួស ឬការចាប់ខ្លួនសត្រូវជាដើម។ និយាយជាសាមញ្ញ អ្នកប្រយុទ្ធ គឺជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៃភាគីជម្លោះ។

អ្នកប្រយុទ្ធ មានកាតព្វកិច្ចគោរពនូវវិធានច្បាប់មនុស្សធម៌អន្តរជាតិ (international humanitarian law)។ ពួកគេ ជាក្រុមគោលដៅរបស់យោធា (military target) អាចទទួលរងនូវការវាយប្រហារ។ នៅក្នុងករណី ពួកគេ ត្រូវបានចាប់ខ្លួន ពួកគេមានឋានៈជាឈ្លើយសឹក (prisoner of war)។

បទប្បញ្ញត្តិ Hague និងមាត្រា ៤នៃ GC III ពង្រីកដាក់បញ្ចូលកងឈ្លប (militia) និងកងស្ម័គ្រចិត្ត ដែលមិនត្រូវបានចុះឈ្មោះក្នុងកងកម្លាំង ទៅក្នុងក្រុមអ្នកប្រយុទ្ធ ក៏ប៉ុន្តែ ត្រូវបំពេញលក្ខខណ្ឌៈ ១. ស្ថិតក្រោមការដឹកនាំ។ ២. មានសញ្ញាសំគាល់ដោយឡែក។ ៣. មានកាន់អាវុធដោយចំហ និង ៤. ប្រតិបត្តិការអនុលោមតាមច្បាប់និងវិធានទំនៀមទម្លាប់នៃសង្គ្រាម (law and custom of war)។

ក្នុងករណីសមាជិកកងកម្លាំង មិនអនុលោមតាមវិធានច្បាប់មនុស្សធម៌ គាត់មិនបាត់បង់បុព្វសិទ្ធិជាអ្នកប្រយុទ្ធទេ តែអាចត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម (war crime)។

ក្នុងសង្គ្រាមស៊ីវិលក្នុងស្រុក (internal armed conflict) កងកម្លាំង មិនមានបុព្វសិទ្ធិជាអ្នកប្រយុទ្ធទេ។ នៅពេលចាប់ខ្លួនបាន ជនទាំងនោះ ដែលមិនបានចូលរួមដោយផ្ទាល់ក្នុងជម្លោះ នឹងទទួលបានការការពារក្រោមមាត្រា៣រួម (common article 3) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 268-270)។